# គោលការណ៍បុគ្គលភាព (Personality Principle)

គោលការណ៍នេះ ជាគោលការណ៍ជាមូលដ្ឋាន ដែលរដ្ឋអាចបង្កើតយុត្តាធិការបាន។ តាមគោលការណ៍នេះ បុគ្គល ដែលមានសញ្ជាតិប្រទេសនោះ អាចជាជនល្មើស ឬជាជនរងគ្រោះ។ ករណីទី ១ គឺជាអ្នកប្រព្រឹត្ត ធ្វើសកម្មភាពទើប គេប្រើពាក្យ “active personality principle”។ ច្បាប់ និងសន្ធិសញ្ញាបានចែងឲ្យបង្កើត ឬផ្តល់សមត្ថកិច្ចដល់រដ្ឋ កាត់ទោសប្រជាពលរដ្ឋខ្លួន ដែលបានប្រព្រឹត្តិបទល្មើសក្រៅប្រទេស។ សម្រាប់ករណីទី២ ប្រជាពលរដ្ឋ នៃប្រទេសមួយ ជាជនរងគ្រោះ នៃបទល្មើស ប្រព្រឹត្តនៅក្រៅប្រទេស (passive personality principle)។

យុត្តាធិការផ្អែកលើបុគ្គលភាពនេះ ប្រឈមនឹងការលំបាកនាពេលអនុវត្ត ដោយសារ បទឧក្រិដ្ឋប្រព្រឹត្តនៅក្រៅប្រទេស។ នៅពេលជនល្មើសត្រឡប់មកស្រុកខ្លួន តែត្រូវបានរដ្ឋដទៃ ស្នើបត្យាប័នទៅវិញដើម្បីទទួលការកាត់ទោស រដ្ឋនៃប្រទេសស៊ីវិលឡូ នឹងជួបបញ្ហា ដោយសារច្បាប់មិនអនុញ្ញាតឲ្យបញ្ជូនជនជាតិខ្លួនទៅក្រៅប្រទេស លើកលែងមានសន្ធិសញ្ញាតម្រូវ។

ការកំណត់យុត្តាធិការ គឺផ្តោតលើបុគ្គលភាព និងយកកត្តាសញ្ជាតិជាមូលដ្ឋាន។ ក្នុងន័យនេះ តើទទួលបានសញ្ជាតិ នាពេលប្រព្រឹត្តបទល្មើស ឬក្នុងអំឡុងពេលចោទប្រកាន់។ ការអនុវត្តរដ្ឋ ហាក់ទទួលយកយុត្តាធិការលើបុគ្គលមានសញ្ជាតិនាពេលចោទប្រកាន់។ បើដូចនេះមែន វាអាចប៉ះដល់គោលការណ៍នីត្យានុកូលភាព (principle of legality) ដោយសារ នាពេលប្រព្រឹត្ត បុគ្គលមិនទាន់មានសញ្ជាតិហើយច្បាប់នោះមិនចង់ដល់គាត់ផងដែរ (គាត់មិនដឹងច្បាប់)។

មានការវិវត្តថ្មី ដោយមិនយកកត្តាសញ្ជាតិជាកំណត់ទេ បុគ្គលដែលមានលំនៅឋាន (residence) ក្នុងរដ្ឋ អាចត្រូវបានចាត់ថាមានចំណង (bond/link)។ នោះពិតជាសំខាន់ក្នុងវិស័យយុត្តិធម៌អន្តរជាតិ ដែលទាមទារនូវយុត្តាធិការទូលាយ ក្តោបលើជនប្រព្រឹត្តជាច្រើនអ្នក (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 451-452)។